**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ផ្ទៃដីទំហំ ១.៩៩០,៥៤ ហិកតា នៅស្រុកស្នួល ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហឺវ៉ាយហ្សិន អេហ្គ្រីខលឈរ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៨៣៦ លក្រច ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីទំហំ ១.៩៩០,៥៨ ហិកតា ចេញដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហឺរ៉ាយហ្សិន អេហ្គ្រី ខលឈ័រ នៃអនុក្រឹត្យលេខ ១៥៨ អនក្រ.បកចុះថ្ងៃទី ៣០វិច្ឆិកា២០១០ ស្តីការធ្វើអនុបយោគផ្ទៃដីទំហំ ៩.៩៩៦ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ ក្នុងនោះ ទំហំ ១,៧៥៥.៩៧ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៣៥.៥៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិថ្គង ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ២**: ត្រូវបានប្រគល់អាណាត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិថ្គង ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៨៨១ ក្បាលដី ជូនប្រជាពលរដ្ឋ ៣១៣ គ្រួសារ

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ឧបសម្ព័ន្ធអនុក្រឹត្យលេខ[illegible] ចុះថ្ងៃទី០៧ ខែ[illegible] ឆ្នាំ២០១៤

ស្តីពីការកាត់ដីទំហំ ១,៩៩០.៥៤ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហ៊ាំហ្សិន អេក្រ្វីងលឈើរ

ស្ថិតនៅ ភូមិថ្កូវ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ

| ID | X | Y | 43 | 647484 | 1345576 | 87 | 649600 | 1343165 |
|---|---|---|---|---|---|---|---|---|
| 0 | 643699 | 1345680 | 44 | 647518 | 1345515 | 88 | 649806 | 1343025 |
| 1 | 643801 | 1346168 | 45 | 647616 | 1345502 | 89 | 649902 | 1342929 |
| 2 | 643873 | 1346215 | 46 | 647687 | 1345461 | 90 | 649908 | 1342828 |
| 3 | 643977 | 1346277 | 47 | 647614 | 1345406 | 91 | 649083 | 1342828 |
| 4 | 644045 | 1346351 | 48 | 647555 | 1345349 | 92 | 649083 | 1341324 |
| 5 | 644192 | 1346355 | 49 | 647587 | 1345261 | 93 | 647579 | 1341324 |
| 6 | 644297 | 1346374 | 50 | 647678 | 1345149 | 94 | 647579 | 1340044 |
| 7 | 644375 | 1346457 | 51 | 647689 | 1345040 | 95 | 647428 | 1340202 |
| 8 | 644588 | 1346383 | 52 | 647731 | 1344989 | 96 | 647147 | 1340237 |
| 9 | 644797 | 1346302 | 53 | 647829 | 1345004 | 97 | 647031 | 1340272 |
| 10 | 644895 | 1346257 | 54 | 647902 | 1345027 | 98 | 646849 | 1340469 |
| 11 | 644918 | 1346162 | 55 | 647978 | 1345008 | 99 | 646795 | 1340594 |
| 12 | 645082 | 1346132 | 56 | 648033 | 1344870 | 100 | 646817 | 1341213 |
| 13 | 645235 | 1346102 | 57 | 647995 | 1344836 | 101 | 646284 | 1341230 |
| 14 | 645348 | 1346081 | 58 | 647912 | 1344757 | 102 | 645746 | 1341232 |
| 15 | 645444 | 1346015 | 59 | 647948 | 1344587 | 103 | 645540 | 1341365 |
| 16 | 645563 | 1346053 | 60 | 648004 | 1344587 | 104 | 645508 | 1341554 |
| 17 | 645701 | 1346102 | 61 | 648078 | 1344563 | 105 | 645524 | 1341681 |
| 18 | 645763 | 1346008 | 62 | 648223 | 1344563 | 106 | 645751 | 1341982 |
| 19 | 645865 | 1345945 | 63 | 648306 | 1344536 | 107 | 645583 | 1342068 |
| 20 | 645918 | 1345893 | 64 | 648308 | 1344429 | 108 | 645675 | 1342374 |
| 21 | 645950 | 1345819 | 65 | 648334 | 1344372 | 109 | 645521 | 1342433 |
| 22 | 646056 | 1345772 | 66 | 648410 | 1344372 | 110 | 645123 | 1342655 |
| 23 | 646112 | 1345706 | 67 | 648461 | 1344387 | 111 | 645113 | 1342782 |
| 24 | 646154 | 1345579 | 68 | 648572 | 1344408 | 112 | 645048 | 1342883 |
| 25 | 646176 | 1345472 | 69 | 648589 | 1344348 | 113 | 645096 | 1342983 |
| 26 | 646250 | 1345457 | 70 | 648627 | 1344276 | 114 | 645072 | 1343110 |
| 27 | 646367 | 1345525 | 71 | 648674 | 1344182 | 115 | 644923 | 1343085 |
| 28 | 646527 | 1345564 | 72 | 648755 | 1344153 | 116 | 644750 | 1343115 |
| 29 | 646591 | 1345621 | 73 | 648819 | 1344104 | 117 | 644623 | 1343259 |
| 30 | 646620 | 1345687 | 74 | 648849 | 1344019 | 118 | 644480 | 1343567 |
| 31 | 646674 | 1345679 | 75 | 648889 | 1343999 | 119 | 644404 | 1343756 |
| 32 | 646772 | 1345651 | 76 | 648925 | 1343929 | 120 | 644288 | 1343865 |
| 33 | 646918 | 1345642 | 77 | 648976 | 1343933 | 121 | 644117 | 1343967 |
| 34 | 647006 | 1345655 | 78 | 649038 | 1343972 | 122 | 643879 | 1344046 |
| 35 | 647050 | 1345702 | 79 | 649087 | 1343980 | 123 | 643663 | 1344227 |
| 36 | 647108 | 1345723 | 80 | 649149 | 1343889 | 124 | 643665 | 1344468 |
| 37 | 647135 | 1345659 | 81 | 649170 | 1343823 | 125 | 643703 | 1344990 |
| 38 | 647184 | 1345602 | 82 | 649121 | 1343736 | 126 | 644209 | 1344966 |
| 39 | 647250 | 1345549 | 83 | 649110 | 1343599 | 127 | 644261 | 1345612 |
| 40 | 647310 | 1345510 | 84 | 649212 | 1343521 | 128 | 643758 | 1345643 |
| 41 | 647346 | 1345544 | 85 | 649417 | 1343395 | | | |
| 42 | 647425 | 1345572 | 86 | 649530 | 1343246 | | | |

សញ្ញាសំគាល់

ផ្លូវក្រាក់

ផ្លូវជាតិលេខ៧

ផ្លូវ

ដីប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់ភូមិថ្កូវ ចំនួន ៣១៣ គ្រួសារ មាន ៤៨១ ក្បាលដី ទំហំ ១៧៧៤.៥៧ ហិកតា




COORDINATE SYSTEM
Projection : UTM
Zone : 48
Horizontal Datum : WGS84
Spheroid : WGS84
Meters
168
149